- សម្របសម្រួល និងពិគ្រោះយោបល់ជាមួយភាគីចិន និងភាគីពាក់ព័ន្ធនានា ដើម្បីជំរុញដល់ការវិនិយោគនៅខេត្តព្រះសីហនុ ទៅតាមគោលនយោបាយ និងចក្ខុវិស័យនៃការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជា។
- ពិនិត្យ និងវាយតម្លៃលើស្ថានភាពនៃការវិនិយោគនៅខេត្តព្រះសីហនុ ដើម្បីកំណត់បញ្ហាប្រឈម និងស្វែងរកដំណោះស្រាយ សំដៅប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណងនាពេលអនាគត ហើយធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន។
- លើកសំណើវិធានការ ក្នុងការដោះស្រាយបញ្ហាប្រឈម និងជំរុញដល់ការវិនិយោគនៅខេត្តព្រះសីហនុ ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសុំការសម្រេចពីរាជរដ្ឋាភិបាលកម្ពុជា។

ប្រការ ៤.-

សមាសភាពនៃក្រុមការងារអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចកោះអញ្ជើញ និងដឹកនាំការប្រជុំ តាមការប្រគល់សិទ្ធិរបស់ប្រធាន។

ប្រការ ៥.-

ក្រុមការងារអន្តរក្រសួងនេះ អាចស្នើសុំកិច្ចសម្របសម្រួល និងសហប្រតិបត្តិការពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជន ដើម្បីពិនិត្យ និងផ្តល់យោបល់ពាក់ព័ន្ធនឹងការជំរុញដល់ការវិនិយោគនៅខេត្តព្រះសីហនុ។

ប្រការ ៦.-

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៥កើត ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤ សសរ

សេចក្តីសម្រេច

ស្តីពី

ការតែងតាំងអនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត
- យោងសេចក្តីណែនាំលេខ ០១ សណន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ក្នុងការបំពេញបេសកកម្ម ដើម្បីត្រួតពិនិត្យ និងគាំទ្រកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ១.-

ត្រូវបានតែងតាំង **ឯកឧត្តម ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាអនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រការ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋបាលខេត្តកំពង់ឆ្នាំង និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេច នេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៥ រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០២០

តប.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

កន្លែងទទួល:

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តមកពីរាជកិច្ចលេខ ៥៧

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៤៧៦ សហវ.ប្រក

ថ្ងៃ អង្គារ ៦ កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩

ប្រកាស
ស្តីពី
ការប្រគល់ភារកិច្ចប្រមូលចំណូលគ្រឹះស្ថានសាធារណៈរដ្ឋបាល សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃ សុក្រ ០៩រោច ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃ សុក្រ ០២កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- តាមការចាំបាច់ដើម្បីអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

សម្រេច

ប្រការ១ .-

ឥណទានចំណូលគ្រឹះស្ថានសាធារណៈរដ្ឋបាលសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ ត្រូវបានបែងចែកលម្អិតតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដូចមានចែងក្នុងសៀវភៅថវិកា ដែលភ្ជាប់នឹងប្រកាសនេះ។

ប្រការ២ .-

រដ្ឋមន្ត្រីគ្រប់ក្រសួង នាយកគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ។

ប្រការ៣ .-

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២០។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

ចម្លងជូនៈ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានថវិកា

នាយកដ្ឋានថវិកានីយកម្ម

ការគ្រប់គ្រងឆ្នាំ ២០២០

ចំណូល ចំណាយថវិកាកម្មវិធីគ្រឹះស្ថានសាធារណៈរដ្ឋបាល

មូលនិធិជនពិការ

ការគ្រប់គ្រងឆ្នាំ ២០២០
ផែនការចំណូលថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល
មូលនិធិជនពិការ

ការអធិប្បាយផែនការនិងសាច់ប្រាក់ថវិកា

ឯកតា៖ លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណូល	ចំណូលប្រចាំឆ្នាំ	សេចក្តីផ្សេងៗ
សរុបរួមចំណូលថវិកា (ក+ខ)				9.998,6	
ក.សរុបចំណូលចរន្ត (ក្រុមទី១ + ក្រុមទី២)				9.998,6	
ក្រុមទី១ : ចំណូលពិត				9.998,6	
ប្រភេទទី ២ : ចំណូលមិនមែនសារពើពន្ធ				9.998,6	
73			ផលចូលពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា	28,0	
	7304		ការផ្តល់សេវាកម្ម	28,0	
		73048	ផលពីសេវាផ្សេងៗទៀត	28,0	
75			ការឧបត្ថម្ភ និង អំណោយ	9.260,5	
	7501		ឧបត្ថម្ភធនពីថ្នាក់ជាតិ	9.095,5	
		75011	ឧបត្ថម្ភធនពីក្រសួង-ស្ថាប័ន	9.095,5	
	7513		ចំណូលពីការចូលរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋាន	165,0	
		75131	ចំណូលពីការចូលរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការអនុវត្តគម្រោង	165,0	
76			ផលហិរញ្ញវត្ថុ	9,8	
	7601		ការប្រាក់នៃការឱ្យខ្ចីនិងការប្រាក់នៃប្រាក់បញ្ញើ	9,8	
		76018	ចំណូលការប្រាក់ផ្សេងទៀត	9,8	
77			ផលផ្សេងៗ និងផលពិសេស	700,3	
	7702		ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ	700,3	
		77021	ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ (លក់)	700,3	

តារាងទី ១

ការគ្រប់គ្រងឆ្នាំ ២០២០

ចំណាយថវិកាតាមចំណាត់ថ្នាក់កម្មវិធី និងតាមអង្គភាពថវិកា

មូលនិធិជនពិការ

ឯកតា៖ លានរៀល

កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព	សរុបឥណទាន	ចំណាត់ថ្នាក់មុខងារ	អង្គភាពថវិកាទទួលខុសត្រូវ
២. កម្មវិធីទី ២ ៖ ការគ្រប់គ្រងរបបសន្តិសុខសង្គម និងសេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ	9.998,6		
២.៣. អនុកម្មវិធីទី ៣ ៖ ស្តារលទ្ធភាពពលកម្មកាយសម្បទា និងការគាំទ្រមុខរបរជនពិការ	9.998,6	71012	2110-មូលនិធិជនពិការ
២.៣.១. ច.សទី ១ ៖ ផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ជូនជនពិការ	4.763,2		
២.៣.២. ច.សទី ២ ៖ ផលិតឧបករណ៍សិប្បនិម្មិត រណប និងហិបសម្បុរសជម៌	1.492,0		
២.៣.៣. ច.សទី ៣ ៖ ផ្តល់របបគោលនយោបាយជួយឧបត្ថម្ភជនពិការ	796,5		
២.៣.៤. ច.សទី ៤ ៖ កិច្ចគាំទ្រដំណើរការរដ្ឋបាល	2.946,9		

តារាងទី ២

ការគ្រប់គ្រងឆ្នាំ ២០២០

ចំណាយថវិកាតាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងតាមជំពូក

មូលនិធិជនពិការ

ឯកតា÷លានរៀល

កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព	សរុបចំណាយថវិកាកម្មវិធី	ចំណាយចរន្ត					
		សរុប	ជំពូក៦០	ជំពូក៦១	ជំពូក៦៤	ជំពូក៦២	ជំពូក៦៣
២. កម្មវិធីទី ២ ៖ ការគ្រប់គ្រងរបបសន្តិសុខសង្គម និងសេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ	9.998,6	9.998,6	6.076,3	2.100,9	971,6	844,5	5,3
២.៣. អនុកម្មវិធីទី ៣ ៖ ស្តារលទ្ធភាពពលកម្មកាយសម្បទា និងការគាំទ្រមុខរបរជនពិការ	9.998,6	9.998,6	6.076,3	2.100,9	971,6	844,5	5,3
២.៣.១. ច.សទី ១ ៖ ផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ជូនជនពិការ	4.763,2	4.763,2	4.312,1	403,1		48,0	
២.៣.២. ច.សទី ២ ៖ ផលិតឧបករណ៍សិប្បនិម្មិត រណប និងហិបសប្បុរសធម៌	1.492,0	1.492,0	1.492,0				
២.៣.៣. ច.សទី ៣ ៖ ផ្តល់របបគោលនយោបាយជួយឧបត្ថម្ភជនពិការ	796,5	796,5				796,5	
២.៣.៤. ច.សទី ៤ ៖ កិច្ចគាំទ្រដំណើរការរដ្ឋបាល	2.946,9	2.946,9	272,2	1.697,8	971,6		5,3

ឧបសម្ព័ន្ធ ៣

ការគ្រប់គ្រងឆ្នាំ ២០២០
ការបែងចែកចំណាយតាមកម្មវិធី អនុកម្មវិធី និងតាមជំពូក គណនី និងអនុគណនី
មូលនិធិជនពិការ

ការអភិវឌ្ឍយកណាមាននិងសារប័ត្រចរិកា | ឯកតា÷លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុបចំណាយថវិកាកម្មវិធី	កម្មវិធីទី២	សេចក្តីផ្សេងៗ
					២.៣.អនុកម្មវិធីទី ៣	
សរុបរួមចំណាយថវិកា (ក+ខ)				9.998,6	9.998,6	
ក. សរុបចំណាយចរន្ត (ក្រុមទី១+ក្រុមទី២)				9.998,6	9.998,6	
ក្រុមទី១ : ចំណាយពិត (ប្រភេទទី១ + ប្រភេទទី២ + ប្រភេទទី៣ + ប្រភេទទី៤)				9.998,6	9.998,6	
ប្រភេទទី១ : មធ្យោបាយ និងសេវា				9.148,8	9.148,8	
60			ការទិញ	6.076,3	6.076,3	
	6001		សម្ភារផ្គត់ផ្គង់ថែទាំ	427,5	427,5	
		60011	សម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ	253,5	253,5	
		60015	ប្រេងឥន្ធនៈ និងប្រេងរំអិល	174,0	174,0	
	6002		សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល	414,4	414,4	
		60021	សម្ភារការិយាល័យ	351,8	351,8	
		60023	ការបោះពុម្ព	62,6	62,6	
	6004		សំលៀកបំពាក់ និងការតុបតែង	64,1	64,1	
		60042	សំលៀកបំពាក់ការពារសុវត្ថិភាព	64,1	64,1	
	6005		សម្ភារតូចតាច សម្ភារទៃ និងសម្ភារបរិក្ខារ	326,3	326,3	
		60053	សម្ភារប្រើប្រាស់	126,3	126,3	
		60054	សម្ភារ និងឧបករណ៍ដឹកជញ្ជូន	200,0	200,0	
	6006		ថាមពលនិងទឹក	215,2	215,2	
		60061	អគ្គិសនី	193,3	193,3	
		60062	ទឹក	21,9	21,9	
	6007		សម្ភារបរិក្ខារថែទាំសុខភាព	4.628,8	4.628,8	
		60072	សម្ភារបរិក្ខារពេទ្យ	489,8	489,8	
		60076	សម្ភារបរិក្ខារថែទាំសុខភាពផ្សេងៗ	4.139,0	4.139,0	
61			សេវាកម្ម	2.100,9	2.100,9	
	6101		កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស	21,7	21,7	
		61011	សេវាអនាម័យ	21,7	21,7	
	6102		ការជួលមធ្យោបាយដឹកជញ្ជូន	8,8	8,8	
		61021	ការជួលមធ្យោបាយដឹកជញ្ជូន	8,8	8,8	
	6105		ការថែទាំនិងជួសជុល	340,6	340,6	
		61052	ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ	113,9	113,9	
		61053	ការថែទាំ ជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ	52,1	52,1	
		61054	ការថែទាំបណ្តាញផ្សេងៗ	35,6	35,6	
		61056	ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន	39,0	39,0	

ឧបសម្ព័ន្ធ ៣

ការគ្រប់គ្រងឆ្នាំ ២០២០
ការបែងចែកចំណាយតាមកម្មវិធី អនុកម្មវិធី និងតាមជំពូក គណនី និងអនុគណនី
មូលនិធិជនពិការ

ការអភិវឌ្ឍហិរញ្ញវត្ថុនិងសាធារណៈការ ឯកតា÷លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុបចំណាយ ថវិកាកម្មវិធី	កម្មវិធីទី២	សេចក្តីផ្សេងៗ
					២.៣.អនុកម្មវិធីទី ៣	
		61057	ការថែទាំនិងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស	51,0	51,0	
		61058	ការថែទាំនិងជួសជុលផ្សេងៗ	49,0	49,0	
	6109		បុគ្គលិកខាងក្រៅ	1.082,8	1.082,8	
		61091	ភ្នាក់ងារជាតិជាប់កិច្ចសន្យា	1.082,8	1.082,8	
	6110		ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ	284,5	284,5	
		61101	សោហ៊ុយទទួលភ្ញៀវជាតិ	28,7	28,7	
		61102	សោហ៊ុយទទួលភ្ញៀវបរទេស	8,9	8,9	
		61103	ប្រជុំ សិក្ខាសាលា និងសន្និសីទ	120,0	120,0	
		61104	ចំណាយរៀបចំពិធីបុណ្យ	31,5	31,5	
		61107	ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ	95,4	95,4	
	6111		សារព័ត៌មាន និងឯកសារ	2,1	2,1	
		61111	ចំណាយលើការជាវសារព័ត៌មាន	2,1	2,1	
	6112		សោហ៊ុយបេសកកម្មក្នុងប្រទេស	311,2	311,2	
		61121	សោហ៊ុយដឹកជញ្ជូន	54,6	54,6	
		61122	សោហ៊ុយបេសកកម្ម	37,5	37,5	
		61123	សោហ៊ុយស្នាក់នៅ	219,1	219,1	
	6113		សោហ៊ុយបេសកកម្មក្រៅប្រទេស	17,2	17,2	
		61131	សោហ៊ុយដឹកជញ្ជូន	8,0	8,0	
		61132	សោហ៊ុយបេសកកម្ម	1,2	1,2	
		61133	សោហ៊ុយស្នាក់នៅ	8,0	8,0	
	6114		សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍	32,0	32,0	
		61141	សោហ៊ុយប្រៃសណីយ៍	3,2	3,2	
		61142	សោហ៊ុយទូរគមនាគមន៍	28,8	28,8	
64			បន្ទុកបុគ្គលិក	971,6	971,6	
	6403		ប្រាក់បំណាច់ផ្សេងៗ	939,4	939,4	
		64037	ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរបស់អង្គភាពដទៃទៀត	76,9	76,9	
		64038	ប្រាក់បំណាច់ផ្សេងៗ	862,5	862,5	
	6405		ប្រាក់វិភាគទានសង្គមសម្រាប់មន្ត្រីរាជការ និងបុគ្គលិកផ្សេងៗ	21,0	21,0	
		64056	គ្រោះថ្នាក់ក្នុងការងារនិងទុព្វលភាព	21,0	21,0	
	6498		បន្ទុកបុគ្គលិកផ្សេងៗទៀត	11,2	11,2	
		64981	បន្ទុកបុគ្គលិកផ្សេងៗទៀត	11,2	11,2	

តារាងទី ៣

ការគ្រប់គ្រងឆ្នាំ ២០២០
ការបែងចែកចំណាយតាមកម្មវិធី អនុកម្មវិធី និងតាមជំពូក គណនី និងអនុគណនី
មូលនិធិជនពិការ

ការអធិប្បាយឥណទាននិងសាលប័ត្រថវិកា

ឯកតា៖ លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុបចំណាយ ថវិកាកម្មវិធី	កម្មវិធីទី២	សេចក្តីផ្សេងៗ
					២.៣.អនុកម្មវិធីទី ៣	
ប្រភេទទី៣ : អន្តរាគមន៍សាធារណៈ				844,5	844,5	
62			**អត្ថប្រយោជន៍សង្គម**	844,5	844,5	
	6202		ជំនួយសង្គមដល់ប្រជាពលរដ្ឋ	294,0	294,0	
		62022	ឱសថ	48,0	48,0	
		62028	ជំនួយសង្គមផ្សេងៗទៀត	246,0	246,0	
	6203		ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌	550,5	550,5	
		62036	ឧបត្ថម្ភមណ្ឌលស្តារលទ្ធភាពពលកម្ម នីតិសម្បទា និងបណ្តុះបណ្តាលអភិវឌ្ឍន៍	550,5	550,5	
ប្រភេទទី៤ : ចំណាយផ្សេងៗ				5,3	5,3	
63			**ពន្ធ និងអាករ**	5,3	5,3	
	6301		លតាប័ត្រ	5,3	5,3	
		63011	លតាប័ត្រ	5,3	5,3	

តារាងទី ៨

ការគ្រប់គ្រងឆ្នាំ ២០២០

ការបែងចែកចំណាយតាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងតាមជំពូក គណនី និងអនុគណនី

មូលនិធិជនពិការ

ការអធិប្បាយគណនាននិងសារប័ព្វថវិកា

ឯកតា៖ លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុបចំណាយថវិកាកម្មវិធី	កម្មវិធីទី២				
					២.៣.អនុកម្មវិធីទី ៣				
					សរុប	ប.សទី ១	ប.សទី ២	ប.សទី ៣	ប.សទី ៤
សរុបរួមចំណាយថវិកា (ក+ខ)				9.998,6	9.998,6	4.763,2	1.492,0	796,5	2.946,9
ក. សរុបចំណាយចរន្ត (ក្រុមទី១+ក្រុមទី២)				9.998,6	9.998,6	4.763,2	1.492,0	796,5	2.946,9
ក្រុមទី១ : ចំណាយពិត (ប្រភេទទី១ + ប្រភេទទី២ + ប្រភេទទី៣ + ប្រភេទទី៤)				9.998,6	9.998,6	4.763,2	1.492,0	796,5	2.946,9
ប្រភេទទី១ : មធ្យោបាយ និងសេវា				9.148,8	9.148,8	4.715,2	1.492,0		2.941,6
60			ការទិញ	6.076,3	6.076,3	4.312,1	1.492,0		272,2
	6001		សម្ភារផ្គត់ផ្គង់ថែទាំ	427,5	427,5	239,1			188,4
		60011	សម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ	253,5	253,5	173,5			80,0
		60015	ប្រេងឥន្ធនៈ និងប្រេងរំអិល	174,0	174,0	65,6			108,4
	6002		សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល	414,4	414,4	366,4			48,0
		60021	សម្ភារការិយាល័យ	351,8	351,8	303,8			48,0
		60023	ការបោះពុម្ព	62,6	62,6	62,6			
	6004		សំលៀកបំពាក់ និងការតុបតែង	64,1	64,1	64,1			
		60042	សំលៀកបំពាក់ការពារសុវត្ថិភាព	64,1	64,1	64,1			
	6005		សម្ភារពួចកាច សម្ភារីម និងសម្ភារបរិក្ខារ	326,3	326,3	290,5			35,8
		60053	សម្ភារប្រើប្រាស់	126,3	126,3	90,5			35,8
		60054	សម្ភារ និងឧបករណ៍ដឹកជញ្ជូន	200,0	200,0	200,0			
	6006		ថាមពលនិងទឹក	215,2	215,2	215,2			
		60061	អគ្គិសនី	193,3	193,3	193,3			
		60062	ទឹក	21,9	21,9	21,9			
	6007		សម្ភារបរិក្ខារថែទាំសុខភាព	4.628,8	4.628,8	3.136,8	1.492,0		
		60072	សម្ភារបរិក្ខារពេទ្យ	489,8	489,8	489,8			
		60078	សម្ភារបរិក្ខារថែទាំសុខភាពផ្សេងៗ	4.139,0	4.139,0	2.647,0	1.492,0		
61			សេវាកម្ម	2.100,9	2.100,9	403,1			1.697,8
	6101		កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស	21,7	21,7	21,7			
		61011	សេវាអនាម័យ	21,7	21,7	21,7			
	6102		ការជួលមធ្យោបាយដឹកជញ្ជូន	8,8	8,8	8,8			
		61021	ការជួលមធ្យោបាយដឹកជញ្ជូន	8,8	8,8	8,8			
	6105		ការថែទាំនិងជួសជុល	340,6	340,6	340,6			
		61052	ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ	113,9	113,9	113,9			
		61053	ការថែទាំ ជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ	52,1	52,1	52,1			
		61054	ការថែទាំបណ្តាញផ្សេងៗ	35,6	35,6	35,6			
		61056	ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន	39,0	39,0	39,0			
		61057	ការថែទាំនិងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស	51,0	51,0	51,0			
		61058	ការថែទាំនិងជួសជុលផ្សេងៗ	49,0	49,0	49,0			
	6109		បុគ្គលិកខាងក្រៅ	1.082,8	1.082,8				1.082,8
		61091	ភ្នាក់ងារជាតិជាប់កិច្ចសន្យា	1.082,8	1.082,8				1.082,8
	6110		ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ	284,5	284,5				284,5
		61101	សោហ៊ុយទទួលភ្ញៀវជាតិ	28,7	28,7				28,7

តារាងទី ៤

ការគ្រប់គ្រងឆ្នាំ ២០២០

ការបែងចែកចំណាយតាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងតាមជំពូក គណនី និងអនុគណនី

មូលនិធិជនពិការ

ការអភិវឌ្ឍសមត្ថភាពនិងសេវាជនពិការ

ឯកតា៖ លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ចំណាយថវិកាឆ្នាំ	កម្មវិធីទី២				
					២.៣.អនុកម្មវិធីទី ៣				
					សរុប	ប.សទី ១	ប.សទី ២	ប.សទី ៣	ប.សទី ៤
		61102	សោហ៊ុយទទួលភ្ញៀវបរទេស	8,9	8,9				8,9
		61103	ប្រជុំ សិក្ខាសាលា និងសន្និសីទ	120,0	120,0				120,0
		61104	ចំណាយរៀបចំពិធីបុណ្យ	31,5	31,5				31,5
		61107	ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ	95,4	95,4				95,4
	6111		សារព័ត៌មាន និងឯកសារ	2,1	2,1				2,1
		61111	ចំណាយលើការជាវសារព័ត៌មាន	2,1	2,1				2,1
	6112		សោហ៊ុយបេសកកម្មក្នុងប្រទេស	311,2	311,2				311,2
		61121	សោហ៊ុយដឹកជញ្ជូន	54,6	54,6				54,6
		61122	សោហ៊ុយបេសកកម្ម	37,5	37,5				37,5
		61123	សោហ៊ុយស្នាក់នៅ	219,1	219,1				219,1
	6113		សោហ៊ុយបេសកកម្មក្រៅប្រទេស	17,2	17,2				17,2
		61131	សោហ៊ុយដឹកជញ្ជូន	8,0	8,0				8,0
		61132	សោហ៊ុយបេសកកម្ម	1,2	1,2				1,2
		61133	សោហ៊ុយស្នាក់នៅ	8,0	8,0				8,0
	6114		សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍	32,0	32,0	32,0			
		61141	សោហ៊ុយប្រៃសណីយ៍	3,2	3,2	3,2			
		61142	សោហ៊ុយទូរគមនាគមន៍	28,8	28,8	28,8			
64			**បន្ទុកបុគ្គលិក**	971,6	971,6				971,6
	6403		ប្រាក់បំណាច់ផ្សេងៗ	939,4	939,4				939,4
		64037	ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរបស់អង្គភាពដទៃ	76,9	76,9				76,9
		64038	ប្រាក់បំណាច់ផ្សេងៗ	862,5	862,5				862,5
	6405		ប្រាក់វិភាគទានសង្គមសម្រាប់មន្ត្រីរាជការ និងបុគ្គលិកផ្សេងៗ	21,0	21,0				21,0
		64056	គ្រោះថ្នាក់ក្នុងការងារនិងទុព្វលភាព	21,0	21,0				21,0
	6498		បន្ទុកបុគ្គលិកផ្សេងៗទៀត	11,2	11,2				11,2
		64981	បន្ទុកបុគ្គលិកផ្សេងៗទៀត	11,2	11,2				11,2
ប្រភេទទី៣ : អន្តរាគមន៍សាធារណៈ				844,5	844,5	48,0		796,5	
62			**អត្ថប្រយោជន៍សង្គម**	844,5	844,5	48,0		796,5	
	6202		ជំនួយសង្គមដល់ប្រជាពលរដ្ឋ	294,0	294,0	48,0		246,0	
		62022	ឱសថ	48,0	48,0	48,0			
		62028	ជំនួយសង្គមផ្សេងៗទៀត	246,0	246,0			246,0	
	6203		ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌	550,5	550,5			550,5	
		62036	ឧបត្ថម្ភមណ្ឌលស្តារលទ្ធភាពពលកម្ម នីតិសម្បទា និងបណ្តុះបណ្តាលអភិវឌ្ឍន៍	550,5	550,5			550,5	
ប្រភេទទី៤ : ចំណាយផ្សេងៗ				5,3	5,3				5,3
63			**ពន្ធ និងអាករ**	5,3	5,3				5,3
	6301		លតាប័ត្រ	5,3	5,3				5,3
		63011	លតាប័ត្រ	5,3	5,3				5,3

តទៅរាជកិច្ចលេខ ៥៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០៣៣២.....សហវ.......

សេចក្តីសម្រេច
ស្តីពី
ការបង្កើតក្រុមការងារជំនាញស្ថិរភាពហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១២១៣ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ ស្តីពី ការបង្កើតគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៩/១៨៣៦ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពី ការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ១ . _

ត្រូវបានបង្កើត **"ក្រុមការងារជំនាញស្ថិរភាពហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"** ដែលមានសមាសភាព ដូចខាងក្រោម÷

១.	**ឯកឧត្តម រស់ សីលវ៉ា**	អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ប្រធាន
២.	**ឯកឧត្តម ម៉ី វ៉ាន់**	ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ	អនុប្រធាន
៣.	**ឯកឧត្តម ទេព តិយ្យោរិន្ទ្រ**	អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ	សមាជិក
៤.	**ឯកឧត្តម អ៊ុង លុយណា**	អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា	សមាជិក
៥.	**ឯកឧត្តម ឈាង វណ្ណារិទ្ធ**	អគ្គនាយករង នៃអគ្គនាយកដ្ឋានគោលនយោបាយ	សមាជិក
៦.	**លោក ឈួន សីរិទ្ធិ**	អគ្គនាយករង នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល	សមាជិក
៧.	**លោក ជូ វណ្ណៈ**	អគ្គនាយករង នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ	សមាជិក
៨.	**លោក អ៊ុន មាត្រា**	ប្រធាននាយកដ្ឋានធានារ៉ាប់រង និងសោធន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ	សមាជិក
៩.	**លោក ណី សាគល**	ប្រធាននាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ	សមាជិក
១០.	**លោក នង ពិសិដ្ឋ**	ប្រធាននាយកដ្ឋានគ្រប់គ្រងអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ	សមាជិក
១១.	**លោក ម៉ាង សុតារ៉ា**	ប្រធាននាយកដ្ឋានគ្រប់គ្រងបំណុល នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល	សមាជិក
១២.	**លោក ជា ភុគ ហុង**	ប្រធាននាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ នៃអគ្គនាយកដ្ឋានគោលនយោបាយ	សមាជិក
១៣.	**លោក សុខ ខន**	ប្រធាននាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច នៃអគ្គនាយកដ្ឋានគោលនយោបាយ	សមាជិក
១៤.	**លោក សោម ផៃ**	ប្រធានការិយាល័យត្រួតពិនិត្យ នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ	សមាជិក
១៥.	**លោកស្រី ចាន់ សុជាតា**	ប្រធានការិយាល័យគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍	

	លំនៅឋាន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ	សមាជិក
១៦. **លោកស្រី តាន់ ឡាលីន**	ប្រធានការិយាល័យ នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ នៃអគ្គនាយកដ្ឋានគោល-នយោបាយ	សមាជិក
១៧. **កញ្ញា សែម សុគា**	ប្រធានការិយាល័យ នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ នៃអគ្គនាយកដ្ឋានគោល-នយោបាយ	សមាជិក
១៨. **លោក ម៉ុត ឆ៉ាន់នី**	ប្រធានការិយាល័យសមាហរណកម្មវិស័យហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ	សមាជិក និងជាលេខាធិការ

ប្រការ២ .-

“ក្រុមការងារជំនាញស្ថិរភាពហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ” ត្រូវបានបង្កើតឡើងក្នុងគោលបំណងតាមដាន និងវាយតម្លៃស្ថិរភាពហិរញ្ញវត្ថុពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងវិះរកវិធានការ ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពវិស័យហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ៣ .-

“ក្រុមការងារជំនាញស្ថិរភាពហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ” មានតួនាទី និងភារកិច្ចដូចតទៅ÷

- តាមដាន វិភាគ និងធ្វើរបាយការណ៍ប្រចាំឆមាសអំពីស្ថានភាពហិរញ្ញវត្ថុ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កំណត់កត្តាហានិភ័យ និងការគំរាមកំហែងនៅក្នុងវិស័យហិរញ្ញវត្ថុ
- សហការជាមួយធនាគារជាតិនៃកម្ពុជា និងគណៈកម្មការមូលបត្រកម្ពុជា ក្នុងការត្រៀមបង្ការទប់ស្កាត់ និងគ្រប់គ្រងវិបត្តិហិរញ្ញវត្ថុ
- ផ្តល់អនុសាសន៍ វិធីសាស្ត្រ និងវិធានការក្នុងការដោះស្រាយវិបត្តិហិរញ្ញវត្ថុ ឱ្យបានទាន់ពេល-វេលា ប្រកបដោយប្រសិទ្ធភាពខ្ពស់ ជូនដល់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំបង្កើតប្រព័ន្ធទិន្នន័យ (Database) សម្រាប់សូចនាករគន្លឹះនៃវិស័យហិរញ្ញវត្ថុ
- បង្កើតម៉ូដែលសម្រាប់វាយតម្លៃលើស្ថិរភាពវិស័យហិរញ្ញវត្ថុ
- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីកសាងសមត្ថភាព និងអភិវឌ្ឍយន្តការទប់ស្កាត់ គ្រប់គ្រង និងដោះស្រាយវិបត្តិហិរញ្ញវត្ថុ
- បំពេញការងារផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ៤ .-

“**ក្រុមការងារជំនាញស្ថិរភាពហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**” មាននាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន។

ប្រការ៥ .-

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ត្រូវរៀបចំ និងផ្តល់របាយការណ៍ប្រចាំត្រីមាសអំពីស្ថានភាពហានិភ័យនៅក្នុងអនុវិស័យហិរញ្ញវត្ថុនីមួយៗនៅក្រោមសមត្ថកិច្ចរបស់ខ្លួន និងសំណើវិធានការដោះស្រាយ រួមទាំងផ្តល់ទិន្នន័យ និងផ្តល់កិច្ចសហប្រតិបត្តិការពេញលេញ សម្រាប់ជាមូលដ្ឋានក្នុងការវាយតម្លៃ និងរៀបចំរបាយការណ៍ស្ថិរភាពវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

ប្រការ៦ .-

“**ក្រុមការងារជំនាញស្ថិរភាពហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**” ត្រូវរៀបចំប្រជុំយ៉ាងតិច ១ដង ក្នុងមួយត្រីមាស និង/ឬ តាមការចាំបាច់ និងត្រូវរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

តាមការអញ្ជើញរបស់ប្រធាន អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំ ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំក្នុងករណីអវត្តមាន ឬមានធុរៈ។

ប្រការ៧ .-

“**ក្រុមការងារជំនាញស្ថិរភាពហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**” មានសិទ្ធិអញ្ជើញមន្ត្រីផ្សេងៗទៀតនៃក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធចូលរួមការងារ និងអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត ចូលរួមកិច្ចប្រជុំ តាមការចាំបាច់។

ប្រការ៨ .-

“**ក្រុមការងារជំនាញស្ថិរភាពហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**” អាចប្រើប្រាស់កញ្ចប់ថវិកានៃ**ក្រុមការងារស្ថិរភាពហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មការមូលបត្រកម្ពុជា** សម្រាប់ដំណើរការងាររដ្ឋបាល ការរៀបចំ និង/ឬ ចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះ បណ្តាលជាតិ និងអន្តរជាតិពាក់ព័ន្ធ ព្រមទាំងការចំណាយចាំបាច់ផ្សេងទៀតក្នុងក្របខណ្ឌរបស់ក្រុម ការងារនេះ។

ប្រការ៩ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១០ .-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ នៃសេចក្តីសម្រេចនេះ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តី សម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

ថ្ងៃសុក្រ ៤រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ មីនា ឆ្នាំ២០២០

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ១០ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០៩០ រ៉ថ.អប្រក.ប្រក

ប្រកាស
ស្ដីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ

លេខ ០០៩០ រ៉ថ.អប្រក.លអ. ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៩

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ចុះថ្ងៃទី០៦ ខែកញ្ញាឆ្នាំ ២០១៨ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ចុះថ្ងៃទី០៩ខែធ្នូឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ស្ដីពីការផ្ទេរនិងសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជា ទៅក្រោមក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០១៥របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការផ្ដល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រកចុះថ្ងៃទី០៣ខែកុម្ភៈឆ្នាំ២០១៧របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០១៥ស្ដីពីការផ្ដល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ខែឧសភាឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៨ ខែមករា ឆ្នាំ ២០១៩ របស់លោកស្រី ប៉ាន់ ស្រីចិន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច

ប្រការ១.-

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈយីហោ ដេប៉ូតេលា ធានី រ៉ែន ចូលី ស្ថិតនៅភូមិស្បៅរីក ឃុំលាច ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ របស់លោកស្រី **ប៉ាន់ ស្រីចិន** (ម្ចាស់ស្ថានីយ) ឲ្យដំណើរការជាបណ្តោះអាសន្ន។

ប្រការ២.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រកចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពលដោយត្រូវបំពេញបន្ថែមនូវឯកសារ ដូចខាងក្រោម រហូតដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នេះ៖

១. ត្រូវមានច្បាប់ថតចម្លងលិខិតអនុញ្ញាតសាងសង់ពីអាជ្ញាធរដែនដី

២. ត្រូវមានច្បាប់ថតចម្លងលិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឲ្យចប់ជាស្ថាពរមុនថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឲ្យមានលំនៅដ្ឋានក្នុងស្ថានីយឡើយ

២. ត្រូវមានកបំពង់ទទួលប្រេងឥន្ធនៈ
៣. ត្រូវមានគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេង
៤. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងបានតែមួយប្រភេទប៉ុណ្ណោះ
៥. ត្រូវបំពាក់គន្លឹះរាសន្ទនៅតាមទូចាក់ប្រេងនីមួយៗ
៦. ត្រូវមានគន្លឹះអាសន្នរួម
៧. ត្រូវមានឧបករណ៍បង្ការពន្លត់អគ្គិភ័យឲ្យបានគ្រប់គ្រាន់
៨. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

ក្នុងករណីដែលម្ចាស់ស្ថានីយមិនធ្វើការកែសម្រួលនូវចំណុចដែលបានរៀបរាប់ខាងលើនេះទេ ក្រសួងរ៉ែ និងថាមពលនិងចេញប្រកាសបិទស្ថានីយប្រេងឥន្ធនៈជាស្ថាពរតែម្តង។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែនិងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែនិងថាមពលមុនប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួនប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១នៃត្រីមាសបន្ទាប់និងប្រចាំឆ្នាំនៅសប្តាហ៍ទី១នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឲ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាតឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាពនៃលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ..០០៩០.១៩ អ.ប្រក.ពរអ..........ចុះថ្ងៃទី....១២....ខែ.មិថុនា..ឆ្នាំ២០១៩....របស់ក្រសួងរ៉ែនិងថាមពល។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០០៩០.១៩ អ.ប្រក.ពរអ ចុះថ្ងៃទី..១២...ខែ...មិថុនា...ឆ្នាំ២០១៩.... នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការប្រធានមន្ទីររ៉ែនិងថាមពលខេត្តពោធិ៍សាត់ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ...១០កើត ខែ..ជេស្ឋ...ឆ្នាំកុរ..ឯកស័ក..ព.ស. ២៥៦៣
ធ្វើនៅភ្នំពេញ ថ្ងៃទី...១២...ខែ.មិថុនា..ឆ្នាំ២០១៩
រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

ស៊ុយ សែម

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាពោធិ៍សាត់
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខៈ ០០៩៦ រថ.អប្រក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០០៩៦ រថ.អប្រក.លអ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៩

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ចុះថ្ងៃទី០៦ ខែកញ្ញាឆ្នាំ ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ស្តីពីការផ្ទេរនិងសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជា ទៅក្រោមក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០១៥របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រកចុះថ្ងៃទី០៣ខែកុម្ភៈឆ្នាំ២០១៧របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០១៥ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង

និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ខែឧសភាឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០១៩ របស់លោកស្រី **ហេង ស៊ីវណេង**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច

ប្រការ១.-

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈយីហោ **ដេប៉ូតេលា ហេង ស៊ីវណេង** ស្ថិតនៅភូមិប្អេរ សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង របស់លោកស្រី **ហេងស៊ីវណេង (ម្ចាស់ស្ថានីយ)** ឲ្យដំណើរការជាបណ្តោះអាសន្ន។

ប្រការ២.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រកចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពលដោយត្រូវបំពេញបន្ថែមនូវឯកសារ ដូចខាងក្រោម រហូតដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ៖

១.ត្រូវមានច្បាប់ថតចម្លងលិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី

២.ត្រូវមានច្បាប់ថតចម្លងលិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។

ប្រការ៤.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឲ្យចប់ជាស្ថាពរមុនថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឲ្យមានលំនៅដ្ឋាន នៅក្នុងបរិវេណស្ថានីយ
២. ពោងប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ១ម៉ែត្រ ពីគ្រឹះសំណង់
៣. ត្រូវផ្ទេរប្រេងឥន្ធនៈចូលពោងប្រេងឥន្ធនៈតាមកបំពង់ទទួលប្រេងឥន្ធនៈ
៤. ត្រូវមានរោងដាក់ពោងប្រេងឥន្ធនៈកប់ក្រោមដី
៥. មិនត្រូវបំពាក់វ៉ាន បិទ បើក នៅលើបំពង់ខ្យល់
៦. ចម្ងាយពីទូចាក់ប្រេងមួយទៅទូចាក់ប្រេងមួយទៀតគួរមានប្រវែង ៧ម៉ែត្រ
៧. ត្រូវបំពាក់គន្លឹះអាសន្នតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ
៨. ទុយោចាក់ប្រេងឥន្ធនៈត្រូវមានប្រវែង ៦ម៉ែត្រ
៩. មិនត្រូវលក់ចែកចាយប្រេងឥន្ធនៈដាក់ប៊ីដុងជ័រក្នុងស្ថានីយ
១០.ទីធ្លាស្ថានីយត្រូវស្រឡះល្អ
១១.ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
១២.ត្រូវមានស្លាកសញ្ញាបម្រាមគ្រប់គ្រាន់។

ក្នុងករណីដែលម្ចាស់ស្ថានីយមិនធ្វើការកែសម្រួលនូវចំណុចដែលបានរៀបរាប់ខាងលើនេះទេ ក្រសួងរ៉ែ និងថាមពលនឹងចេញប្រកាសបិទស្ថានីយប្រេងឥន្ធនៈជាស្ថាពរតែម្តង។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែនិងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែនិងថាមពលមុនប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួនប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១នៃត្រីមាសបន្ទាប់និងប្រចាំឆ្នាំនៅសប្តាហ៍ទី១នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឲ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាតឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាពនៃលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ...០០៩៨ រ.ថ.អ.ប.ក.ល.រ.........ចុះថ្ងៃទី....២៤....ខែ...មិថុនា.ឆ្នាំ២០១៩....របស់ក្រសួងរ៉ែនិងថាមពល។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ ០០៩៨ រ.ថ.អ.ប.ក.ល.រ ចុះថ្ងៃទី..២៤...ខែ..មិថុនា.....ឆ្នាំ២០១៩.... នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការប្រធានមន្ទីររ៉ែនិងថាមពលខេត្តកំពង់ឆ្នាំង និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ...៧រោច....ខែ..ជេស្ឋ...ឆ្នាំកុរ...ឯកស័ក...ព.ស. ២៥៦៣

ធ្វើនៅភ្នំពេញ ថ្ងៃទី...២៤.....ខែ.មិថុនា...ឆ្នាំ២០១៩

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

ស៊ុយ សែម

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ឆ្នាំង
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី